# **សម័យប្រជុំព្រឹកថ្ងៃអាទិត្យ**

ថ្ងៃទី 6 ខែ មេសា ឆ្នាំ 2008

## **សេចក្តីជំនឿនៃព្រះវរបិតារបស់យើង**

ប្រធានដាយធើ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ

*សាសនាពិតមិនគួរចាប់ផ្តើមចេញមកពីអ្វីដែលបំពេញចិត្តរបស់មនុស្ស ឬទំនៀមទំលាប់របស់ជីដូនជីតាទេ ប៉ុន្តែចេញមកពីអ្វីដែលបំពេញព្រះហឫទ័យរបស់ព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចរបស់យើង ។*

យើងត្រូវបានប្រទានពរខ្លាំងណាស់ ដោយសារតន្ត្រីដ៏ពិរោះរបស់ក្រុមចំរៀងរោងឧបោសថ ។ បងប្អូនប្រុសស្រី និងមិត្តភក្តិ ទាំងឡាយជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំរីករាយដែលឈរជាមួយនឹងអ្នកនៅថ្ងៃនេះ ក្នុងការមានឱកាសដ៏មហិមានៃការហៅខ្លួនរបស់ខ្ញុំថាជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយដែលត្រូវបានរាប់ជាមនុស្សម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា ។

ខ្ញុំនៅចាំពីប្រតិកម្មរបស់ខ្ញុំនៅពេលដែលខ្ញុំបានទទួលការហៅដ៏ពិសិដ្ឋនេះមកពីព្រះអម្ចាស់ ដើម្បីបម្រើជាសមាជិកថ្មីបំផុត នៃគណៈប្រធានទីមួយនៃសាសនាចក្រនេះ---ខ្ញុំទទួលនូវអារម្មណ៍ *រីករាយយ៉ាងសន្ធោសន្ធៅ* ។ ចាប់ពីពេលនោះមកខ្ញុំ បានរៀននូវទំហំថ្មីនៃពាក្យថា *សេចក្តីរាបសា អំណរគុណ* និង *សេចក្តីជំនឿ* ។

ខ្ញុំចង់បញ្ជាក់ដល់អ្នកថា គ្មាននរណាម្នាក់ដែលមានការភ្ញាក់ផ្អើលចំពោះការហៅរបស់ខ្ញុំជាងកូន១ និងចៅ១របស់ខ្ញុំនោះទេ ។

នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងមិនស្វែងរក ឬយើងបដិសេធនឹងនូវការហៅដែលមកពីព្រះតាមរយៈពួកអ្នកដឹកនាំបព្វជិតភាពដែលបានទទួលការបំផុសគំនិតនោះទេ ។ ខ្ញុំសូមអធិស្ឋានថា ព្រះនឹងផ្តល់ឱ្យខ្ញុំនូវកម្លាំងដើម្បីស្អាងការហៅដ៏ពិសិដ្ឋនេះ ស្របតាមព្រះទ័យ និងព្រះរាជបំណងរបស់ទ្រង់ ។

យើងទាំងអស់គ្នានឹកដល់ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ។ កម្លាំងរបស់លោកចំពោះកិច្ចការដ៏មហិមានេះនឹងបន្តប្រទានពរដល់យើង ។

ខ្ញុំមានអារម្មណ៍ថាមានឯកសិទ្ធិខ្លាំងណាស់ក្នុងការធ្វើការយ៉ាងជិតស្និទ្ធនឹងប្រធានម៉នសុន ។ ខ្ញុំបានស្គាល់លោកអស់ជា ច្រើនឆ្នាំមកហើយ ។ លោកគឺជាបុរសនៃអំណោយទាន និងទេព្យកោសល្យដ៏អស្ចារ្យ ។ លោកគឺជាព្យាការីនៃព្រះ ។ សេចក្តីជំនឿ និងដួងចិត្តនៃសេចក្តីស្រឡាញ់របស់លោក បានពង្រីកដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ។

ខ្ញុំមានអំណរគុណក្នុងការបំរើជាមួយនឹងប្រធានអាវិង ជាអ្នកដែលខ្ញុំស្រឡាញ់ ហើយគោរពជាអ្នកដឹកនាំដ៏មហិមា និងជាគ្រូបង្រៀននៅក្នុងនគរនៃព្រះ ។

នៅពេលក្រុមនៃពួក 12 នាក់បានជួបជុំគ្នានៅបន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធទីក្រុងសលត៍ លេក ដើម្បីធ្វើការគាំទ្រ ដល់ប្រធាន ម៉នសុន ជាប្រធាននៃសាសនាចក្រទី 16 ខ្ញុំបានមានការស្ញប់ស្ញែងនូវសមត្ថភាពដ៏ខុសពីធម្មតា ប្រាជ្ញា និងជីវភាពខាងវិញ្ញាណនៃអ្នកដែលនៅជុំវិញខ្ញុំ ។ វាបានធ្វើឱ្យខ្ញុំដឹងកាន់តែច្បាស់ថែមទៀតនូវភាពមិនពេញលេញរបស់ ខ្ញុំ ។ ខ្ញុំស្រឡាញ់បុរសដ៏ល្អៗទាំងនេះនៃសេចក្តីជំនឿដ៏មហិមា ។ ខ្ញុំមានអំណរគុណចំពោះឱកាសដើម្បីលើកដៃរបស់ខ្ញុំគាំទ្រ ហើយផ្តល់នូវការគាំទ្ររបស់ខ្ញុំដល់ពួកលោក ។ ខ្ញុំពិតជាស្រឡាញ់ ហើយគាំទ្រ គ្រីស្ទហ្វឺសិន ជាសមាជិកថ្មីបំផុតនៃពួក 12 នាក់ ។

នៅពេលព្រះអម្ចាស់បានហៅ ហ្វ្រែតឌើរិក ជី វីល្លាម ដើម្បីធ្វើជាទីប្រឹក្សាដល់ព្យាការីយ៉ូសែប ស្ម៊ីធ ទ្រង់បានបញ្ជា ដល់គាត់ឱ្យ "ចូរមានចិត្តស្មោះត្រង់ចុះ ចូរឈរនៅក្នុងតំណែងដែលយើងបានតែងតាំងដល់អ្នក ចូរជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរចំរើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង" ។[1] ខ្ញុំជឿថាពាក្យទូន្មាននេះនៅតែអនុវត្ត ចំពោះមនុស្សទាំងអស់ណាដែលទទួលយកការហៅបំរើនៅក្នុងនគរនៃព្រះ ---ហើយយ៉ាងជាក់ច្បាស់ចំពោះខ្ញុំនៅក្នុងរដូវកាលនេះនៃជីវិតរបស់ខ្ញុំ ។

## ជាព្យាការីនៃព្រះ និងជាប្រធានរបស់យើង

ខ្ញុំសូមនិយាយអំពីប្រធានថូម៉ាស អេស ម៉នសុន ពីរបីម៉ាត់ ។ កាលពីប៉ុន្មានឆ្នាំកន្លងទៅហើយ ប្រធាន ម៉នសុន បានមកចូល រួមនៅក្នុងសន្និសីទនៃភូមិភាគនៅទីក្រុង ហែមប៊ើហ្គ ប្រទេសអាល្លឺម៉ង់ ហើយនោះគឺជាកិត្តិយសរបស់ខ្ញុំដើម្បីរួមដំណើរ ជាមួយលោក ។ ប្រធាន ម៉នសុន មាននូវការចងចាំដ៏អស្ចារ្យ ហើយយើងបានជជែកគ្នាអំពីពួកបរិសុទ្ធជាច្រើននៅ ប្រទេសអាល្លឺម៉ង់---ខ្ញុំមានការស្ញប់ស្ញែងថា លោកចងចាំបានយ៉ាងល្អបំផុត ។

ប្រធានម៉នសុន បានសួរអំពីបងប្រុស មីហ្កែល ផានីតស៍ ជាអតីតប្រធានស្តេក ហើយក្រោយមកបានធ្វើជាលោកអយ្យកោដែលលោកគឺជាអ្នកត្រួសត្រាយផ្លូវមួយរូបដ៏រឹងមាំម្នាក់នៃសាសនាចក្រនៅក្នុងប្រទេសអាល្លឺម៉ង់ ។ ខ្ញុំបានជំរាបលោកថា បងប្រុស ផានីតស៍ មានជម្ងឺយ៉ាងធ្ងន់ធ្ងរ ដែលលោកនៅលើគ្រែមួយកន្លែង ហើយមិនអាចចូលរួមនៅក្នុងការប្រជុំរបស់យើងបានទេ ។

ប្រធានម៉នសុន បានសួរបើយើងអាចទៅសួរសុខទុក្ខគាត់ ។ ខ្ញុំដឹងថាមិនយូរប៉ុន្មាន ពីមុនដំណើររបស់លោកទៅកាន់ទីក្រុងហែមប៊ើហ្គ ប្រធាន ម៉នសុន បានទទួលការវះកាត់ជើងយ៉ាងធ្ងន់ធ្ងរ ហើយថាលោកមិនអាចដើរបានដោយគ្មានការឈឺចាប់នោះទេ ។ ខ្ញុំបានពន្យល់លោកជាបងប្រុស ផានីតស៍ រស់នៅជាន់ទីប្រាំនៃអគារដែលគ្មានជណ្តើរយន្តនោះទេ ។ យើងត្រូវតែដើរឡើងតាមជណ្តើរដើម្បីទៅសួរសុខទុក្ខគាត់ ។

ប៉ុន្តែប្រធានម៉នសុន បានទទូចចង់ទៅ ។ ហើយដូច្នោះយើងក៏បានទៅ ។ ខ្ញុំចងចាំថាវាពិបាកយ៉ាងណាសំរាប់ ប្រធាន ម៉នសុន ដើម្បីដើរឡើងកាំជណ្តើរទាំងនោះ ។ លោកអាចដើរម្តងតែពីរបីកាំប៉ុណ្ណោះ ពីមុនត្រូវឈប់ហើយសំរាក ។ លោកមិនដែលបន្លឺសម្លេងរអ៊ូរទាំមួយម៉ាត់សោះ ហើយលោកមិនអាចត្រឡប់ក្រោយវិញទេ ។ ពីព្រោះអគារនោះមានដំបូលខ្ពស់កាំជណ្តើរហាក់ដូចជាទៅមុខជារៀងរហូត ប៉ុន្តែប្រធាន ម៉នសុននៅបន្តទៅមុខដោយរីករាយ រហូតដល់យើងបានទៅដល់បន្ទប់របស់បងប្រុស ផានីតស៍នៅជាន់ទីប្រាំ ។

នៅពេលទៅដល់ទីនោះ យើងបានធ្វើការសួរសុខទុក្ខដ៏អស្ចារ្យមួយ។ ប្រធាន ម៉នសុន បានអរគុណដល់គាត់សំរាប់ជីវិតនៃការបំរើដ៏ពលិកម្មរបស់គាត់ ហើយលើកទឹកចិត្តដល់គាត់ជាមួយនឹងស្នាមញញឹម។ ពីមុនយើងបានចាកចេញ លោកបានធ្វើការប្រសិទ្ធពរបព្វជិតភាពយ៉ាងអស្ចារ្យដល់គាត់។

បងប្រុស ផានីតស៏ ក្រុមគ្រួសាររបស់គាត់ និងរូបខ្ញុំមិនដែលធ្លាប់ឃើញនូវទង្វើរដ៏ក្លាហាន និងសេចក្តីមេត្តាករុណាបែបនោះពីមុនមកទេ។

ប្រធានម៉នសុន អាចជ្រើសរើសយកការសំរាកនៅចម្លោះការប្រជុំដ៏យូរ និងញឹកញាប់របស់យើង។ លោកអាចសុំ ដើរមើលទីកន្លែងដ៏ស្រស់ស្អាតនៃក្រុងហែមបើហ្គ ។ ជាញឹកញាប់ ខ្ញុំបានគិតថាទីកន្លែងទាំងឡាយនៅក្នុងទីក្រុងវាអស្ចារ្យណាស់ តែអ្វីដែលលោកចង់ទៅមើលជាងទីកន្លែងផ្សេងៗទៀតនោះ គឺជាសមាជិកនៃសាសនាចក្រដែលដេកមានជម្ងឺនៅលើគ្រែ ដែលបានបំរើដល់ព្រះអម្ចាស់ដោយស្មោះត្រង់ និងបន្ទាបខ្លួនទៅវិញ។

ប្រធានម៉នសុន បានមកហែមបើហ្គ ដើម្បីបង្រៀន ហើយប្រសិទ្ធពរដល់ប្រជាជនក្នុងប្រទេស ហើយនោះគឺជាអ្វី ដែលលោកបានធ្វើ។ ប៉ុន្តែនៅក្នុងពេលដូចគ្នានោះ លោកបានផ្តោតយកចិត្តទុកដាក់ទៅលើបុគ្គលម្នាក់ៗតាមឈ្មោះ។ ការយល់ដឹងរបស់លោកគឺធំទូលាយណាស់ ហើយលូកដៃទៅយ៉ាងឆ្ងាយដើម្បីចាប់នូវការស្មុគស្មាញនៃសាសនាចក្រទូទាំងពិភពលោក ប៉ុន្តែលោកក៏មានសេចក្តីមេត្តាករុណាយ៉ាងខ្លាំង ដើម្បីផ្តោតយកចិត្តទុកដាក់ទៅលើមនុស្សម្នាក់ៗផងដែរ។

នៅពេលដែលសាវក ពេត្រុស និយាយពីព្រះយេស៊ូវ ដែលទ្រង់បានធ្វើជាមិត្តភក្តិ ហើយជាគ្រូបង្រៀនរបស់គាត់ គាត់បានផ្តល់ឱ្យនូវការពិពណ៌នាដ៏សាមញ្ញនេះថា: "[ទ្រង់] បានយាងចុះឡើងធ្វើការល្អ"។[2]

ខ្ញុំមានអារម្មណ៍ដូចគ្នានេះ ដែលអាចនិយាយអំពីបុរសដែលយើងបានគាំទ្រនៅថ្ងៃនេះជាព្យាការីនៃព្រះ។

## សេចក្តីជំនឿនៃព្រះវរបិតារបស់យើង

ខ្ញុំមានការស្ញប់ស្ញែងនូវជីវប្រវត្តិខុសៗគ្នានៃសមាជិកទាំងឡាយនៃសាសនាចក្រ។ អ្នកបានមកពីសង្គម វប្បធម៌ ភាសា និងកាលៈទេសៈនយោបាយ ហើយទំនៀមទំលាប់ខាងសាសនាខុសៗគ្នា។

បទពិសោធន៍នៃក្រុមជីវិតដ៏ធំនេះបានបណ្តាលឱ្យខ្ញុំ សញ្ជឹងគិតអំពីសារលិខិតនៃទំនុកដំកើងមួយរបស់យើងគឺបទ "ឱព្រះបិតា"។ ជាការបន្ទរ ពាក្យពេចន៍ទាំងនេះត្រូវបាននិយាយម្តងទៀតថា: "សេចក្តីជំនឿនៃព្រះវរបិតាយើង សេចក្តីជំនឿដ៏ស្មោះត្រង់ យើងនឹងពិតចំពោះទ្រង់រហូតដល់ស្លាប់! "[3]

សេចក្តីជំនឿនៃព្រះវរបិតារបស់យើង---ខ្ញុំស្រឡាញ់ឃ្លានោះ។

ត្បិតសមាជិកជាច្រើននៃសាសនាចក្រ ពាក្យពេចន៍ទាំងនេះបាននាំដល់គំនិតនៃពួកអ្នកត្រួសត្រាយផ្លូវដ៏ក្លាហាន ដែលបានបោះបង់ចោលផ្ទះដ៏សុខស្រួលរបស់ពួកគេ ហើយបានធ្វើដំណើរដោយរទេះ ហើយដើរដោយជើងទទេរហូតដល់ពួកគេ បានទៅដល់ជ្រលងភ្នំដ៏ធំនៃសលត៍ លេក។ ខ្ញុំស្រឡាញ់ ហើយគោរពសេចក្តីជំនឿ និងសេចក្តីក្លាហាននៃពួកអ្នកត្រួសត្រាយកាលពីដើមឡើយនៃសាសនាចក្រ។ បព្វការីជនរបស់ខ្ញុំផ្ទាល់បានរស់នៅឆ្លងកាត់មហាសមុទ្រនៅពេលនោះ។ គ្មាននរណា ម្នាក់ដែលបានរស់នៅក្នុងក្រុង ណៅវូ ឬវិនធើ ឃ្វតធើរស៍ឡើយ ហើយគ្មាននរណា

ម្នាក់បានធ្វើដំណើរឆ្លងកាត់ ទីវាលរហោស្ថាននោះទេ។ ប៉ុន្តែក្នុងនាមជាសមាជិកមួយរូបនៃសាសនាចក្រ ខ្ញុំសូមប្រកាសដោយអំណរគុណ និងអំនួតនូវកេរដំណែលនៃពួកអ្នកត្រួសត្រាយផ្លូវទាំងនេះដូចជាខ្ញុំបានធ្វើដែរ។

ជាមួយនឹងសេចក្ដីអំណរដូចគ្នានោះ ខ្ញុំសូមប្រកាសនូវកេរដំណែលនៃពួកអ្នកត្រួសត្រាយផ្លូវសព្វថ្ងៃនេះនៃសម័យទំនើបនៃសាសនាចក្រ ដែលបានរស់នៅគ្រប់ប្រទេស និងដំណើររឿងផ្ទាល់ខ្លួនរបស់ពួកគេអំពីការព្យាយាម សេចក្ដីជំនឿ និងការពលិកម្ម បន្ថែមនូវឃ្លាដ៏រុងរឿងថ្មីមួយទៀត ចំពោះចំរៀងដ៏មហិមានៃការគោរពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ នៃនគររបស់ព្រះ។

នៅពេលក្រុមគ្រួសាររបស់ខ្ញុំបានសញ្ជឹងគិតពីឃ្លា "សេចក្ដីជំនឿនៃព្រះវរបិតារបស់យើង" ជាញឹកញាប់វាគឺជាសេចក្ដីជំនឿខាងលូស្សៀរវែន ដែលផុសឡើងនៅក្នុងគំនិត។ អស់ជាច្រើនជំនាន់បព្វការីជនរបស់យើងបានរួមចំណែកនៅក្នុងនិកាយនោះ។ ជាការពិតណាស់ កូនប្រុសរបស់ខ្ញុំថ្មីៗនេះបានរកឃើញថា មនុស្សម្នាក់នៅក្នុងវង្សត្រកូលរបស់យើងជាប់ខ្សែនឹងម៉ាទីន លូស្សៀរ។

យើងផ្ដល់កិត្តិយស និងគោរពនូវព្រលឹងដ៏ស្មោះត្រង់នៅគ្រប់សាសនាទាំងអស់ មិនថាឡើយនៅទីណា ឬនៅពេលណា ដែលពួកគាត់បានរស់នៅនោះទេ ដែលពួកគាត់ស្រឡាញ់ព្រះ ទោះបីជាគ្មាននូវភាពពេញលេញនៃដំណឹងល្អក្ដី។ យើងបន្លឺសម្លេងរបស់យើងឡើងនៅក្នុងអំណរគុណសំរាប់ភាពមិនអត្តានិយម និងសេចក្ដីក្លាហានរបស់ពួកគេ។ យើងឱបក្រសោបពួកគេជាបងប្អូនប្រុសស្រីរបស់យើង ជាកូនចៅនៃព្រះវរបិតាសួគ៌របស់យើង។

យើងជឿថា វាគឺជាមូលដ្ឋាននៃសិទ្ធិមនុស្សក្នុងការជ្រើសរើសដើម្បីថ្វាយបង្គំ "ដ៏មានមហិទ្ធិឫទ្ធិស្របតាមការណែនាំនៃ សម្បជញ្ញៈរបស់យើងខ្ញុំ ហើយសូមបណ្ដោយឱ្យមនុស្សទាំងអស់មានសិទ្ធិដូចគ្នា ចូរឱ្យគេថ្វាយបង្គំរបស់របៀបណា នៅទីណាឬអ្វីក៏ដោយដែលពួកគេប្រាថ្នា"។[4]

**មានសេចក្ដីជំនឿ និងទំនៀមទំលាប់ជាច្រើននៃព្រះវរបិតារបស់យើង**

ក្នុងនាមជាសាសនាចក្រដែលបានស្ដារឡើងវិញ នៃព្រះយេស៊ូវគ្រីស្ទ នៅទូទាំងពិភពលោក---ឥឡូវមានសមាជិកជាង 13 លាននាក់---"សេចក្ដីជំនឿនៃព្រះវរបិតារបស់យើង" បានពង្រីកនូវនិយមន័យ។ ត្បិតអ្នកខ្លះវាអាចសំដៅទៅលើ កេរដំណែលរបស់ក្រុមគ្រួសាររបស់ពួកគេនៅក្នុងចំណោមសេចក្ដីជំនឿនៃពួកគ្រីស្ទានរាប់រយនាក់ ចំពោះអ្នកដទៃទៀត វាអាចសំដៅទៅលើសេចក្ដីជំនឿ និងទំនៀមទំលាប់របស់ពួកភូមិភាគកណ្ដាលប៉ែកខាងកើត ពួកអាស៊ី ឬពួកអាហ្វ្រិក។

ខ្ញុំបានចំណាយពេលភាគច្រើននៃជីវិតរបស់ខ្ញុំនៅក្នុងតំបន់នៃពិភពលោក ដែលសមាជិកទាំងឡាយនៃសាសនាចក្រគឺមានចំនួនតិច។ នៅអំឡុងពេលដែលខ្ញុំរៀនពីការណ៍នោះជាញឹកញាប់ នៅពេលប្រជាជនរៀនពីដំណឹងល្អដែលបានស្ដារឡើងវិញ ពួកគេមានចំណាប់អារម្មណ៍ដោយសារការណ៍នោះ---មនុស្សជាច្រើនថែមទាំងចង់ចូលរួមនៅក្នុងសាសនាចក្រ។ ប៉ុន្តែពួកគេមានចិត្តស្ទាក់ស្ទើរ ពីព្រោះពួកគេមិនចង់ធ្វើឱ្យជីដូនជីតារបស់ពួកគេខកបំណង ពួកគេមានអារម្មណ៍ថាពួកគេគួរតែពិតចំពោះសេចក្ដីជំនឿនៃជីដូនជីតារបស់ពួកគេ។

ខ្ញុំនៅចាំនៅពេលដែលខ្ញុំនៅក្មេង នៅថ្ងៃអាទិត្យ ខ្ញុំបានឃើញក្រុមគ្រួសារថ្មីមួយនៅក្នុងសាលាប្រជុំរបស់យើង---ម្តាយវ័យក្មេងជាមួយនឹងកូនស្រីពីរនាក់។ វាមិនយូរប៉ុន្មាន ពីមុនពួកគេបានទទួលបុណ្យជ្រមុជទឹក ហើយបានក្លាយជាសមាជិកនៃសាសនាចក្រ។

ខ្ញុំដឹងនូវរឿងនៃការផ្លាស់ប្រែចិត្តជឿរបស់ពួកគេយ៉ាងជិតស្និត ពីព្រោះឈ្មោះរបស់កូនស្រីច្បងគឺ ហែរីត ហើយក្រោយមកនាងបានក្លាយជាភរិយារបស់ខ្ញុំ។

ម្តាយរបស់ហែរីត លោកស្រីខាមែន ស្វាមីរបស់គាត់ទើបបានទទួលមរណភាព ហើយនៅអំឡុងពេលការសាកល្បងមើល គាត់ក៏បានចាប់អារម្មណ៍នឹងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ បន្ទាប់ពីការសិក្សានូវគោលលទ្ធិទាំងឡាយ លោកស្រីខាមែន និងកូនស្រីរបស់គាត់បានដឹងថាសាសនាចក្រគឺពិត ហើយបានរៀបផែនការទទួលបុណ្យជ្រមុជទឹក។

នៅពេលលោកស្រីខាមែន បានប្រាប់ម្តាយរបស់គាត់អំពីការសំរេចចិត្តនោះ ទោះជាយ៉ាងណាក្តី ម្តាយរបស់គាត់បានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ គាត់បានសួរថា: "តើឯងអាចមិនស្មោះត្រង់ចំពោះជំនឿនៃជីដូនជីតារបស់ឯងយ៉ាងម៉េចកើត?

ម្តាយរបស់លោកស្រីខាមែន មិនមែនគ្រាន់តែជាមនុស្សម្នាក់ដែលបានជំទាស់នោះទេ។ បងស្រីលីសា មានឆន្ទៈដ៏មោះមុតរបស់លោកស្រីខាមែន បានឃាត់ឃាំងដោយសារតែព័ត៌មានមិនល្អ។ ប្រហែលជាពាក្យថា *មិនល្អ* គឺជាពាក្យដែលទន់ភ្លន់ជាងក្នុងការនិយាយ។ គាត់ខឹងខ្លាំងណាស់។

លីសា បាននិយាយថាគាត់នឹងទៅរកពួកអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងទាំងនោះ ហើយប្រាប់ពួកគេថាពួកគេខុសឆ្គងយ៉ាងខ្លាំង។ គាត់បានដើរដំរង់ទៅរោងថ្វាយបង្គំ ហើយបានឃើញពួកអ្នកផ្សព្វផ្សាយសាសនា ប៉ុន្តែអ្នកទាយទៅមើលថាយ៉ាងម៉េច លីសា ក៏បានទទួលបុណ្យជ្រមុជទឹកដែរ។

ជាច្រើនឆ្នាំកន្លងទៅហើយម្តាយរបស់លោកស្រីខាមែន ក៏បានទទួលទីបន្ទាល់ថាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទបានត្រូវស្តារឡើងនៅលើផែនដីផងដែរ។ នៅថ្ងៃមួយគាត់បាននិយាយទៅកាន់កូនស្រី និងចៅៗរបស់គាត់ថា: "ខ្ញុំចង់រស់នៅស្ថានសួគ៌ជាមួយនឹងចៅៗ ហើយកូនៗទាំងអស់គ្នា"។ ខណៈដែលនៅវ័យពាក់កណ្តាល 70 ឆ្នាំគាត់បានចូលទៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹកផងដែរ ហើយបានក្លាយជាសមាជិកនៃសាសនាចក្រ។

## សេចក្តីជំនឿនៃព្រះវរបិតារបស់យើង

បន្ទាប់មកទៀត តើជាសេចក្តីជំនឿនៃឪពុករបស់យើងឬ? វាគឺជាសាសនាសំរាប់ឪពុកម្តាយ លោកតាលោកយាយ និងលោកតាលោកយាយតួតរបស់យើងឬ?

ប៉ុន្តែចុះចំណែកសេចក្តីជំនឿនៃអ្នកពីបុរាណពីមុនពួកគេ? តើចំណែកលោកអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបវិញ? តើពួកលោក មិនមែនជាជីដូនជីតារបស់យើងទេឬអី? តើយើងមិនមែនជាវង្សនៃអ៊ីស្រាអែលទេឬអី? ចុះចំណែកណូអេ និងអេណុក ហើយឪពុកម្តាយដំបូងរបស់យើង លោកអ័ដាម និងអេវ៉ា?

ចុះចំណែកព្រះអង្គសង្គ្រោះ និងពួកសិស្សទាំងនោះដែលបានធ្វើតាមទ្រង់?

សេចក្ដីជំនឿនៃព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌បានមានចាប់តាំងពីចាប់ផ្ដើមមកម្ល៉េះ គឺចាប់តាំងពីកំណើតលោកិយមក យ៉ូហានជាអ្នកទទួលវិវរណៈបានពិពណ៌នានូវសង្គ្រាមដ៏ធំនៅស្ថានសួគ៌។ 5 បញ្ហាគឺថាសេរីភាពជ្រើសរើស ខាងសីលធម៌មិដូចដែលមាននៅសព្វថ្ងៃនេះ។ ជនទាំងឡាយណាដែលធ្លាប់រស់នៅលើផែនដីនេះនៅក្នុងចំណោមជនទាំងឡាយណាដែលបានច្បាំងប្រឆាំងនឹងសាតាំង ហើយបានឈរជាមួយព្រះរាជបុត្រានៃព្រះវរបិតា។ ហេតុដូច្នេះហើយ តើយើងមិនជំពាក់ភក្ដីភាពរបស់យើងចំពោះព្រះជាព្រះវរបិតាសួគ៌របស់យើងទេឬអី?

ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ "យើងខ្ញុំជឿដល់ព្រះគឺព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់ព្រះវិញ្ញាណបរិសុទ្ធ"។ 6 ហើយ "យើងជឿថាតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាមក្រឹត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ"។ 7 យើងជឿលើផែនការដ៏មហិមានៃព្រះអង្គសង្គ្រោះ ផែនការនៃការប្រោសលោះដែលកូនចៅរបស់ព្រះអាចមាននូវបទពិសោធន៍នៃជីវិតរមែងស្លាប់ ហើយត្រឡប់ទៅវត្តមាននៃព្រះវរបិតាវិញ---ផែនការប្រកបដោយសេចក្ដីមេត្តាករុណាបានស្ថាបនាឡើងតាំងពីកំណើតផែនដីមក។

នេះគឺជាផែនការ និងសេចក្ដីជំនឿនៃព្រះវរបិតារបស់យើង!

ខ្ញុំសូមថ្លែងទីបន្ទាល់នូវគោលលទ្ធិនៃដំណឹងល្អដែលបានស្ដារឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ គឺជាសេចក្ដីជំនឿនៃព្រះវរបិតា សួគ៌របស់យើង។ គឺសេចក្ដីពិតរបស់ទ្រង់ត្រូវបានបើកសម្ដែងដល់ពួកអ្នកបំរើរបស់ទ្រង់ជាព្យាការីចាប់តាំងពីសម័យនៃ ឪពុកអ័ដាមរបស់យើង រហូតដល់សម័យរបស់យើង។ ព្រះវរបិតា និងព្រះរាជបុត្រាបានយាងមកជួបយ៉ូសែប ស្ម៊ីធ ដើម្បីស្ដារសេចក្ដីជំនឿនៃព្រះវរបិតារបស់យើងនៅលើផែនដី ហើយនិងមិនដកយកពីផែនដីជាថ្មីម្ដងទៀតទេ។ ព្រះមានព្រះរាជបំណងឱ្យកូនចៅរបស់ទ្រង់ទាំងអស់ទទួលដំណឹងល្អ មិនថាជីវប្រវត្តិ វប្បធម៌ ឬទៀមទំលាប់របស់ពួក គេមកពីណានោះទេ។ សាសនាពិតប្រាកដមិនគួរចាប់ផ្ដើមឡើងពីអ្វីដែលធ្វើឱ្យមនុស្សពេញចិត្ត ឬទំនៀមទំលាប់នៃជីដូនជីតានោះទេ តែផ្ទុយទៅវិញចេញពីអ្វីដែលសព្វព្រះទ័យដល់ព្រះ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង។

វិវរណៈដែលកំពុងមានជាបន្តគឺគោលការណ៍គ្រឹះនៃសាសនា។ ការអធិស្ឋានដំបូងរបស់យ៉ូសែប ស្ម៊ីធគឺជាទីបន្ទាល់ដ៏មានអំណាចនៃកិច្ចការនេះ។ វិវរណៈគឺមាននូវត្រីវិស័យដែលរក្សាយើងឱ្យនៅពិតជានិច្ចចំពោះឆន្ទៈ និងសេចក្ដីជំនឿនៃ ព្រះវរបិតាសួគ៌របស់យើង។

ព្រះវរបិតាសួគ៌របស់យើងស្រឡាញ់កូនចៅរបស់ទ្រង់។ ទ្រង់ស្ដាប់ឮនូវការអធិស្ឋានដ៏រាបទាប និងស្មោះត្រង់នៃគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា។ ទ្រង់ប្រទានពន្លឺដល់ជនទាំងឡាយណាដែលស្វែងរក ហើយគោរពដល់ទ្រង់ ហើយមានឆន្ទៈដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់។ យើងសូមប្រកាសដោយរីករាយថា សេចក្ដីជំនឿនៃ ព្រះវរបិតារបស់យើងគឺនៅលើផែនដីនេះ។

យើងសូមអញ្ជើញមនុស្សគ្រប់រូបដែលរស់នៅលើពិភពលោកនេះ ឱ្យភ្លក់នូវគោលលទ្ធិរបស់ទ្រង់ ហើយមើលបើសិនជា វាមិនផ្អែមល្ហែម ហើយល្អ និងមានតម្លៃនោះ។ យើងសូមឱ្យអ្នកទាំងឡាយណាដែលមានចិត្តស្មោះសដើម្បីរៀនពីគោលលទ្ធិនេះ ហើយសូមសួរដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់ពួកគេ បើវាមិនមែនជាការពិត។

ហើយដោយសារការធ្វើបែបនោះ មនុស្សទាំងអស់អាចរកឃើញ ឱបក្រសោប ហើយដើរនៅក្នុងសេចក្តីពិតនៃជំនឿលើព្រះវរបិតារបស់ពួកគេ ជាសេចក្តីជំនឿដែលធ្វើឱ្យពួកគេបានសុខសាន្ត។8

នោះគឺជាសារលិខិតរបស់យើងចំពោះពិភពលោកទាំងមូល។

ខ្ញុំសូមថ្លែងទីបន្ទាល់យ៉ាងឧឡារិកពីការពិតនៃព្រះជាព្រះវរបិតា ព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធ និងព្យាការីដែលនៅរស់ ដែលកាន់កូនសោទាំងអស់ ដែលបានក្លាយជាការស្ទងដំណែងដែលមិនអាចបំបាក់បាន ចាប់តាំងពីលោកយ៉ូសែប ស្ម៊ីធ ដល់លោកថូម៉ាស អេស ម៉នសុន នៅសព្វថ្ងៃនេះ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. គ. និង ស. 81:5។

2. កិច្ចការ 10:38។

3. *ទំនុកដំកើងទំព័រ* 84។

4. មាត្រានៃសេចក្តីជំនឿ 1:11។

5. សូមមើលវិវរណៈ 12:7-9។

6. មាត្រានៃសេចក្តីជំនឿ 1:1។

7. មាត្រានៃសេចក្តីជំនឿ 1:3។

8. សូមមើល ម៉ាថាយ 9:22។